ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា នេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — ព្រះហស្ថលេខា និង ត្រា — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — ហត្ថលេខា និង ត្រា — **ហ៊ុន សែន**

* * *

## III - ការងារបណ្ដាក្រសួង

## ពីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៤

## ប្រកាស លេខ ០០៣ ប្រក.សហវ

## ស្ដីពីការគ្រប់គ្រងឃ្លាំងបេឡានៃធនាគារជាតិ

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាសម្ដេច ព្រះនរោត្តម សីហនុ ក្នុង ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង គណៈរដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥ អ.ន.ក្រ ចុះថ្ងៃទី ២០-៩-៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួង ហិរញ្ញវត្ថុ
- តាមសំណើរបស់លោកប្រធាន ធនាគារជាតិ

### សំរេច

មាត្រា ១ : ឃ្លាំងបេឡា នៃធនាគារជាតិមានតែមួយគត់ ។ ជារៀងរាល់ថ្ងៃត្រូវមានឃ្លាំងបេឡាចរន្ត

មួយដែលបង្កើតឡើងដោយយកមូលនិធិចេញពីឃ្លាំងបេឡាបំរុងមកប្រើការ និង ចាត់ចែង ទទួលប្រាក់ចំណូលព្រមទាំងបើកប្រាក់ចំណាយប្រចាំថ្ងៃ ។

**មាត្រា ២ :** យោលទៅតាមការងារជាក់ស្តែងរបស់ធនាគារជាតិ ឃ្លាំងបេឡាចរន្តត្រូវមានទូដែកមួយ ឬ ច្រើនដែលលោកប្រធានការិយាល័យឃ្លាំងបេឡាជាអ្នកកាន់សោ ។

**មាត្រា ៣ :** លោកប្រធានការិយាល័យឃ្លាំងបេឡា និង លោកប្រធានធនាគារជាតិ ត្រូវប្រុងប្រយ័ត្ន ដើម្បីអោយកិច្ចប្រតិបត្តិការខាងឃ្លាំង បេឡាចរន្តប្រព្រឹត្តទៅអោយមាន លក្ខណៈសម្បត្តិ សន្តិសុខដាច់ខាត ។

**មាត្រា ៤ :** ក្រោយពីកិច្ចប្រតិបត្តិការមួយថ្ងៃ ៗ មូលនិធិនៅក្នុងឃ្លាំងបេឡាចរន្តត្រូវបញ្ចូលទៅក្នុងឃ្លាំង បេឡាបំរុងវិញជាដាច់ខាត ក្រោយពីការពិនិត្យដ៏ម៉ត់ចត់ពីស្ថានភាព នៃប្រាក់ ចំណូល និង ប្រាក់ ចំណាយ ។

**មាត្រា ៥ :** ឃ្លាំងបេឡាបំរុងមានភារៈខាងការផ្តល់ប្រាក់ និង ដោះស្រាយការខ្វះខាតសាច់ប្រាក់ អោយ ឃ្លាំងបេឡាចរន្ត ។

**មាត្រា ៦ :** ឃ្លាំងបេឡាបំរុងមានលេណភូមិ ឬ ទូប្រាក់ដែលលោកប្រធានការិយាល័យឃ្លាំងបេឡា និង លោកប្រធានធនាគារជាតិជាអ្នក បើកបិទគ្រប់គ្រាដែលត្រូវការដកយកឬ ទុកដាក់ប្រាក់ ធនប័ត្រ ឬលិខិតបេឡា ។ លោកប្រធានការិយាល័យឃ្លាំងបេឡា និង លោកប្រធានធនាគារ ជាតិត្រូវមានវត្តមានជានិច្ចនៅ ឱកាសធ្វើប្រតិបត្តិការ បញ្ចូល ឬ បញ្ចេញប្រាក់ក្នុងឃ្លាំង បេឡាបំរុងរហូត ដល់ ចប់កិច្ចការសព្វគ្រប់ ។

**មាត្រា ៧ :** ទ្វារលេណភូមិ ឬ ទូប្រាក់ នៃឃ្លាំងបេឡាបំរុងត្រូវចាក់សោបើកបិទដោយអាស្រ័យកូនសោ ពីរយ៉ាងតិច ដែលត្រូវលោកប្រធានការិយាល័យឃ្លាំងបេឡាជាអ្នកកាន់មួយ និង មួយទៀត ត្រូវ លោកប្រធានធនាគារជាតិជាអ្នកកាន់ ។

ហាមដាច់ខាតមិនអោយលោកប្រធានការិយាល័យឃ្លាំងបេឡា និងលោកប្រធានធនាគារជាតិកាន់កូនសោទាំងពីរនេះតែម្នាក់ឯង ទោះបីស្ថិតនៅក្នុងកាលៈទេសៈណា ក៏ដោយ ។

**មាត្រា ៨ :** លោកប្រធានការិយាល័យឃ្លាំងបេឡា និង លោកប្រធានធនាគារជាតិ ត្រូវតែទុកកូនសោ របស់ខ្លួនក្នុងទូដែកនៅការិយាល័យរៀង ៗ ខ្លួន ។

**មាត្រា ៩ :** កូនសោ ដែលសំរាប់ប្រើ ត្រូវអោយមានត្រឹមតែពីរគត់ កូនសោ ទីពីរព្រមទាំងលេខ សម្ងាត់ គ្រឿងសោ នៃលេណភូមិ ឬ ទូប្រាក់ត្រូវអ្នកកាន់កូនសោ ច្រកក្នុងស្រោម បិទជោះ

ត្រា ហើយផ្ញើទុកក្នុងទូដែកនៅធនាគារជាតិរាជធានីភ្នំពេញ ក្រោមការទទួលខុសត្រូវផ្ទាល់របស់លោកប្រធាន ធនាគារជាតិ ។

**មាត្រា ១០:** លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋាន បុគ្គលិក លោកប្រធាន ធនាគារជាតិ និង លោកប្រធានគ្រប់គ្រងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

**មាត្រា ១១:** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១-០១-១៩៩៤ តទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៩៤

## ប្រកាស លេខ ០០៤ ប្រក.កហទ

## ស្តីពី

## ការគ្រប់គ្រងឃ្លាំងបេឡានៅធនាគារខេត្ត - ក្រុង

* * *

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ២០-៨-៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងហិរញ្ញវត្ថុ
- តាមសំណើរបស់លោកប្រធាន ធនាគារជាតិ